# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម

សំណុំរឿង០០២ ▪របាយការណ៍លេខ ៦៤ ▪សវនាការលើកស្តុតាង ▪សប្តាហ៍ទី ៥៩ ▪ ថ្ងៃទី១៧ -២០ មិថុនា ឆ្នាំ ២០១៣



ករណីរបស់ជនជាប់ចោទលោក **នួន ជា** និងលោក **ខៀវ សំផន**

**Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center***

*នៅពេលនោះ ខ្ញុំនៅក្មេងណាស់ ហើយការគោរពតាមវិន័យរបស់អង្គការ គឺគ្រាន់តែជារឿងធម្មតាប៉ុណ្ណោះ។ អ្នកគ្រប់គ្នា ត្រូវតែគោរព និងអនុវត្តតាមវិន័យបែបនោះ។ វាជារឿងធម្មតា។*[1]

**សាក្សី ឡេង ឈឿង**

## ផ្នែកទី ១ ៖ ទិដ្ឋភាពទូទៅ

នៅសប្តាហ៍នេះ អង្គជំនុំជម្រះ បានសាកសួរសាក្សីពីររូប ដែលអ្នកទាំងពីរសុទ្ធតែជាអតីតកម្មាភិបាលខ្មែរក្រហម ដែលបានផ្តល់សក្ខីកម្មសំខាន់ ទាក់ទងនឹងតួនាទីរបស់សហជនជាប់ចោទ។ លោក **ឡេង ឈឿង** បានរៀបរាប់អំពីតួនាទីរបស់គាត់ជាអ្នកបើកបរឲ្យលោក **ខៀវ សំផន** មុនពេលដួលរលំនៅទីក្រុងភ្នំពេញ នៅខែមករា ឆ្នាំ១៩៧៩។ សាក្សីម្នាក់ទៀតឈ្មោះ **នូ ម៉ៅ** បានផ្តល់សក្ខីកម្មថា គាត់បានដឹងអំពីផែនការរបស់ថ្នាក់ដឹកនាំគណបក្សកុម្មុយនីស្តកម្ពុជា ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ទោះជាយ៉ាងណា គាត់មិនបានដឹងច្បាស់ទេថា ជនជាប់ចោទ **ខៀវ សំផន** បានគាំទ្រគោលនយោបាយជម្លៀសនេះដែរឬទេ។ គាត់ក៏បានផ្តល់ព័ត៌មានអំពីជោគវាសនារបស់ទាហាន **លន់ នល់** ដែលមកដល់ឃុំរបស់គាត់ បន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥។

បញ្ហាផ្លូវច្បាប់ និងនីតិវិធីជាច្រើនបានកើតឡើងនៅពេញមួយសប្តាហ៍ ហើយបញ្ហាដែលគួរឱ្យកត់សម្គាល់បំផុត គឺទាក់ទងនឹងការប្រើប្រាស់កំណត់ហេតុកិច្ចសម្ភាសន៍របស់លោក **បែន ឃៀរនិន** (Mr. Ben Kiernan) ក្នុងអំឡុងពេលនៃការសាកសួរសាក្សី **នូ ម៉ៅ**។ ទោះបីជាសាក្សី ត្រូវបានអ្នកប្រវត្តិសាស្ត្រ **បែន ឃៀរនិន** បាន

សម្លាសក្នុងឆ្នាំ១៩៨១ ក៏ដោយ ក៏គាត់មិនធ្លាប់ត្រូវបានសម្ភាសជាផ្លូវការ ដោយការិយាល័យសហចៅក្រមស៊ើបសួរនោះទេ។ បញ្ហានីតិវិធីផ្សេងទៀតអំពី អញ្ញត្រកម្ម ជាបន្តបន្ទាប់ត្រូវបានលើកឡើង ពាក់ព័ន្ធនឹងការសាកសួរដដែលៗ និងការប៉ាន់ស្មានរបស់សាក្សី។ ក្រៅពីបញ្ហាទាំងនេះ សវនាការបានប្រព្រឹត្តអស់រយៈពេលបីថ្ងៃ ដោយគ្មានបញ្ហាធំដុំទាក់ទងនឹងការគ្រប់គ្រងសវនាការនោះឡើយ។

## ផ្នែកទី ២ ៖ សក្ខីកម្មសង្ខេបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី

នៅសប្តាហ៍នេះ អង្គជំនុំជម្រះ បានបើកសវនាការលើការផ្តល់សក្ខីកម្មរបស់អតីតកម្មាភិបាលថ្នាក់ទាបរបស់ខ្មែរក្រហមពីរនាក់ គឺលោក **ឡុង ឈឿង** និងលោក **នូ ម៉ៅ** ហៅ "**ម៉ុក**"។ ចាប់ពីឆ្នាំ១៩៧៨ ដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ លោក **ឡុង ឈឿង** បានធ្វើជាអ្នកបើកបរផ្ទាល់ឱ្យលោក **ខៀវ សំផន**។ គាត់បានផ្តល់ព័ត៌មានបានស៊ីជម្រៅទាក់ទងនឹងជីវិតផ្ទាល់ខ្លួនរបស់គាត់។ ការសាកសួរលោក **នូ ម៉ៅ** ដែលអតីតជាសិប្បករម្នាក់ នៅរបបខ្មែរក្រហម គឺបានពឹងផ្អែកយ៉ាងខ្លាំងទៅលើបទសម្ភាសន៍មួយជាមួយលោក **ប៊ែន ឃៀរនិន** នៅឆ្នាំ១៩៨១។ លោក **នូ ម៉ៅ** បាននិយាយអំពីប្រធានបទជាច្រើន ក្នុងអំឡុងសម័យកម្ពុជាប្រជាធិតេយ្យ រួមមានកម្លាំងខ្មែរ វៀតមិញ ការប្រព្រឹត្តចំពោះព្រះសង្ឃ និងទាហាន **លន់ នល់**។

### ក. សក្ខីកម្មរបស់ ឡុង ឈឿង (TCW- 384)

សាក្សី **ឡុង ឈឿង** ជាបុរសមានវ័យ ៥០ ឆ្នាំម្នាក់ ដែលបច្ចុប្បន្នកំពុងបម្រើការងារជាអនុប្រធាននៅការិយាល័យស្ថិតិបាត់ដំបង នៅស្រុកសំពៅលូន។ លោក **ឡុង ឈឿង** ត្រូវបានក្រុមមេធាវីការពារក្តីលោក **ខៀវ សំផន** ស្នើឱ្យធ្វើជាសាក្សី ដែលពាក់ព័ន្ធនឹងអត្តចរិត ហើយបានផ្តល់សក្ខីកម្មស្តីពីបទពិសោធន៍របស់គាត់ជាអ្នកបើកបរផ្ទាល់របស់លោក **ខៀវ សំផន** ចាប់ពីចុងឆ្នាំ១៩៧៨ ដល់ខែមករា ឆ្នាំ១៩៧៩។[2] ទាក់ទងទៅនឹងស្ថានភាពដែលបានជួបប្រទះក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យនោះវិញ លោក **ឡុង ឈឿង** បានផ្តល់សក្ខីកម្មថា គាត់មិនមានអារម្មណ៍ថា ខ្មែរក្រហម បានប្រព្រឹត្តអ្វីមិនល្អលើរូបគាត់ទេ ហើយបន្ថែមថា គាត់មានអារម្មណ៍ "ធម្មតា"។ ទោះបីជាសាក្សីបានរម្លឹកថា ជាញឹកញាប់ គាត់នឹកស្រុកកំណើត និងគ្រួសារគាត់ តែគាត់បានបញ្ជាក់ថា គាត់បានចូលរួមបដិវត្តន៍ដោយស្ម័គ្រចិត្ត ហើយមានអារម្មណ៍ថា គាត់មានការទទួលខុសត្រូវលើការបំពេញការងារ ដែលចាត់តាំងមកឱ្យគាត់។

#### *ក.១. បទពិសោធន៍មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥*

លោក **ឡុង ឈឿង** មានអាយុ ១០ឆ្នាំ នៅពេលដែលគាត់បានចូលរួមបដិវត្តន៍ក្នុងឆ្នាំ១៩៧៣ ដែលផ្ទុយពីបំណងប្រាថ្នារបស់ឪពុកម្តាយគាត់។ សាក្សី បានប្រាប់តុលាការអំពីរឿងមេភូមិម្នាក់ បានទៅកាន់សាលារៀនរបស់គាត់នៅខេត្តតាកែវ ហើយបានសួរថា តើសិស្សទាំងនោះមានចំណាប់អារម្មណ៍ចូលរួមក្នុងបដិវត្តន៍ដែរ

ឬទេ? គាត់បាននិយាយថា “អ្នកគ្រប់គ្នា សុទ្ធតែលើកដៃ ដូច្នេះយើងក៏ចូលរួមជាមួយពួកគេតែម្តង”។[3] បន្ទាប់ពីបានរំដោះខេត្តតាកែវ បានហើយនោះ លោក **ឡេង ឈឿង** ត្រូវបានចាត់តាំងឱ្យកសាងទំនប់ទឹក នៅអង្គភាពកុមារមួយ ស្ថិតនៅត្រាំងខ្នា។ តាមការចងចាំរបស់គាត់ គ្មាននរណាម្នាក់ត្រូវបានបង្ខំឱ្យធ្វើការនៅកន្លែងនោះទេ ហើយអ្នកដែលឈឺត្រូវអនុញ្ញាតឱ្យសម្រាកនៅផ្ទះ។ ទោះជាសាក្សី មិនអាចរម្លឹកអំពីវិន័យជាក់លាក់ណាមួយនៅក្នុងអង្គភាពក៏ដោយ តែគាត់បាននិយាយច្បាស់ថា “គ្មាននរណាម្នាក់មានសេរីភាពធ្វើអ្វី ដែលពួកគេចង់ធ្វើនោះទេ”។ ទោះបីជាគាត់មានមហិច្ឆតាចង់រួមចំណែកដល់ការបដិវត្តន៍នេះក៏ដោយ តែគាត់នៅតែថា គាត់នឹកស្រុកកំណើតរបស់គាត់ ជាអារម្មណ៍មួយដែលបណ្តាលឱ្យគាត់ "យំយ៉ាងខ្លាំង" នៅពេលនោះ។ ទោះជាយ៉ាងណា គាត់បានពន្យល់ទៅតុលាការថា គាត់មានអារម្មណ៍ថា គាត់គ្មានជម្រើសអ្វីក្រៅពីបន្តនៅជាមួយខ្មែរក្រហម។

### *ក.២. បទពិសោធន៍ស្នាក់នៅ ក-១២ និងបញ្ជូនបន្តទៅ ក-៣*

ក្នុងឆ្នាំ១៩៧៦ លោក **ឡេង ឈឿង** ត្រូវបានបញ្ជូនទៅភ្នំពេញ ដើម្បីចូលរៀននៅសាលាបច្ចេកទេសខ្មែរសូវៀត ភាគច្រើនស្គាល់ថាជា **ក-១២**។ អស់រយៈពេលពីរឆ្នាំ គាត់បានសម្អាតផ្ទះនៅម្តុំសាលារៀនក្រោមការមើលការខុសត្រូវរបស់ **តា មៀល**។ គាត់ក៏បានរៀនបើកឡាននៅពេលនៅទីនោះ ហើយវាជាជំនាញមួយ ដែលអាចធ្វើគាត់បានក្លាយជាអ្នកបើកបរផ្ទាល់របស់ **ខៀវ សំផន**។ សាក្សីបាននឹកឃើញវិញថា គាត់ត្រូវបានបញ្ជូនទៅ **ក-៣** ដើម្បីទទួលតំណែងថ្មី នៅអំឡុងពីខែសីហា ដល់ខែវិច្ឆិកា ឆ្នាំ១៩៧៨។ លោក **ឡេង ឈឿង** បានបញ្ជាក់ថា គាត់បានឮអំពីការបាត់ខ្លួនរបស់កម្មាភិបាលដទៃទៀត។ ទោះជាយ៉ាងណា ទាក់ទិននឹងការបាត់ខ្លួនរបស់អតីតមេការរបស់គាត់ឈ្មោះ **តា មៀល** នេះ សាក្សីបានអះអាងថា គាត់មិនបានដឹងអំពីរឿងនោះទេ រហូតដល់ពេលដែលគាត់ត្រូវបានបញ្ជូនទៅ **ក-៣**។ ការបកស្រាយរបស់គាត់ផ្ទុយពីបញ្ជីអ្នកទោស ស-២១ ដែលអយ្យការបានបង្ហាញដល់សាក្សី ដែលបានចុះកាលបរិច្ឆេទនៃការចាប់ខ្លួនរបស់ **តា មៀល** នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៨។

### *ក.៣. បទពិសោធន៍រស់នៅ និងធ្វើការនៅ ក-៣*

លោក **ឡេង ឈឿង** បានបម្រើការងារជាអ្នកបើកឡានផ្ទាល់ឱ្យលោក **ខៀវ សំផន** ចាប់ពីចុងឆ្នាំ១៩៧៨ រហូតដល់ពេលដែល **ខៀវ សំផន** បានភៀសខ្លួនចូលទៅកាន់ព្រៃភ្នំ នៅពេលដែលវៀតណាមបានមកដល់ប្រទេសកម្ពុជា។ សាក្សីបានរម្លឹកថា បុគ្គលម្នាក់ ដែលត្រូវគេស្គាល់ថាឈ្មោះ “**សាមី**” ជាអ្នកគ្រប់គ្រង **ក-៣** និងបានមើលការខុសត្រូវគាត់ក្នុងអំឡុងពេលនេះ។ សាក្សីបានផ្តល់សក្ខីកម្មថា គាត់បានរស់នៅចម្ងាយប្រហែល ១០ ម៉ែត្រពីផ្ទះ **ខៀវ សំផន** នៅបរិវេណ **ក-៣**។ គាត់បានពន្យល់ថា បរិវេណនោះមានទីតាំងនៅក្បែរព្រះបរមរាជវាំង នៅក្នុងម្តុំ ដែលមានអាគារចំនួនប្រហែល២០។ អាគារដែលមានសភាពល្អ ត្រូវបានកាន់កាប់ ហើយអាគារផ្សេងៗទៀត ត្រូវបានបោះបង់ចោល។ សាក្សីបានពិពណ៌នាអំពីផ្ទះរបស់ **ខៀវ សំផន** ថាជា “កន្លែងធម្មតា” មួយ ហើយបន្ថែមថា គាត់គ្មានការិយាល័យ ឬលេខា ហើយឃើញមានតែសង្ហារិមតិចតួចប៉ុណ្ណោះ ហើយនិងទូរសព្ទមួយ។ លោក **ឡេង ឈឿង** បានសារភាពថា គាត់មិនធ្លាប់បានចូលក្នុងផ្ទះរបស់ **ខៀវ សំផន** ទេ ប៉ុន្តែដឹងអំពីព័ត៌មាននេះ

តាមរយៈការមើលទៅក្នុងផ្ទះ តាមរយៈទ្វារកញ្ចក់ខាងមុខ។ សាក្សី ក៏បានពន្យល់ដែរថា ផ្ទះរបស់ **នួន ជា** និង **អៀង សារី** មានទីតាំងនៅម្ខាងទៀតនៃផ្លូវ។ សាក្សី បានពន្យល់ថា នៅ **ក-៣** ពុំសូវមានអាហារច្រើនទេ ប៉ុន្តែគាត់មានអារម្មណ៍ពេញចិត្តចំពោះរបបដែលគាត់ទទួលបាន។ សាក្សីបានបញ្ជាក់ថា ប្រពន្ធរបស់លោក **ខៀវ សំផន** ធ្វើការនៅផ្ទះបាយមួយនៅ **ក-៣** បន្ថែមថា កម្មករត្រូវបរិភោគអាហារនៅផ្ទះបាយផ្សេងមួយទៀត។

### *ក.៤. ការដឹងអំពីសកម្មភាពរបស់ ខៀវ សំផន*

លោក **ឡេង ឈឿង** បានផ្តល់សក្ខីកម្មថា ពីរបីដងក្នុងមួយសប្តាហ៍ គាត់បានបើកបរជូនលោក **ខៀវ សំផន** ទៅប្រជុំ ដែលមានចម្ងាយបួនគីឡូម៉ែត្រពី **ក-៣** ទៅ **ក-១** ដែលគាត់បានប៉ាន់ប្រមាណថា មានរយៈពេលប្រហែល ៣០នាទី ទៅមួយម៉ោង។ កិច្ចប្រជុំទាំងនោះ ធ្វើឡើងជាមួយលោក **នួន ជា** និងលោក **អៀង សារី** ដោយការពិតឃើញថា អ្នកបើកបរផ្ទាល់របស់ពួកគាត់ បានប្រមូលផ្តុំគ្នានៅក្រៅបរិវេណ។ សាក្សី បានលើកឡើងថា គាត់ធ្លាប់បានបើកបរជូនលោក **ខៀវ សំផន** ចេញពីក្រុងភ្នំពេញ បានពីរដងប៉ុណ្ណោះ គឺម្តងទៅខេត្តកណ្តាល និងម្តងទៀតទៅខេត្តតាកែវ។[4] ជួនកាល គាត់បើកបរឱ្យ **ខៀវ សំផន** នៅម្តុំភ្នំពេញ ប៉ុន្តែក្នុងអំឡុងពេលធ្វើដំណើរម្តងៗ **ខៀវ សំផន** មិនបានចាកចេញពីរថយន្តនោះទេ។ គាត់បានចាំនៅពេលដ៏សំខាន់មួយ នៅពេលដែលគាត់បានបើកបរជូនលោក **ខៀវ សំផន** ទៅកាន់កិច្ចប្រជុំធំមួយនៅស្តាតអូឡាំពិច។ នៅពេលគាត់កំពុងរង់ចាំ គាត់បានលឺតាមសំឡេងមេក្រូថា **ប៉ុល ពត** និង **នួន ជា** ក៏បានចូលរួមក្នុងព្រឹត្តិការណ៍នោះដែរ។ យោងតាមការបង្ហាញពីអារម្មណ៍របស់សាក្សី **ប៉ុល ពត** ធ្វើជាប្រធានក្នុងព្រឹត្តិការណ៍នោះ ហើយ **ខៀវ សំផន** មិនបាននិយាយទៅកាន់អ្នកចូលរួមទេ។

ចៅក្រម **ឡាវ៉ែន** បានសួរថា តើចាំបាច់ត្រូវមានការអនុញ្ញាតជាពិសេសដែរឬទេ ដើម្បីបើកបរទៅក្រៅទីក្រុងភ្នំពេញ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ? លោក **ឡេង ឈឿង** បានឆ្លើយថា ពុំមានកន្លែងត្រួតពិនិត្យឡើយ ហើយគាត់ក៏មិនចាំបាច់មានលិខិតអនុញ្ញាតអ្វីដែរ។ សាក្សីក៏ត្រូវបានចោទសួរផងដែរថា លើកចុងក្រោយដែលគាត់បានបើកបរឱ្យលោក **ខៀវ សំផន**។ លោក **ឡេង ឈឿង** បានប្រាប់តុលាការថា នៅម៉ោង ៧ ល្ងាច នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដោយគ្មានការរៀបចំជាមុន ឬរៀបចំបង្វិចអ្វីឡើយ គាត់បានបើកបរឱ្យ **ខៀវ សំផន** តែឯងចេញពីទីក្រុងភ្នំពេញ។ ពួកគាត់បានបើកបរពីទីក្រុងភ្នំពេញទៅខេត្តពោធិ៍សាត់ ជាកន្លែងដែល **ខៀវ សំផន** បានជួបជាមួយ **នួន ជា** និង **ប៉ុល ពត** មុនបើកបរទៅខេត្ត ប៉ៃលិន។ នៅខេត្ត ប៉ៃលិន លោក **ឡេង ឈឿង** បានរម្លឹកថា គាត់ និងលោក **ខៀវ សំផន** បានឡើងភ្នំមួយ ហើយក៏បានចែកផ្លូវគ្នាទៅ។

### *ក.៥. តួនាទី និងចរិតលក្ខណៈរបស់ជនជាប់ចោទ*

លោក **ឡេង ឈឿង** បានពិពណ៌នាអំពីជនជាប់ចោទថា ជាបុរសសុភាព និងមានចិត្តល្អ ដែលរស់នៅក្នុងជីវិតដ៏សាមញ្ញ។ សាក្សីបានលើកឡើងថា ក្នុងគំនិតរបស់គាត់ លោក **ខៀវ សំផន** ក៏មិនមានអំណាចអ្វីណាស់

ណាដែរនៅក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហម។ លោក **ឡេង ឈឿង** បានពន្យល់ថា មូលហេតុតែមួយគត់ ដែលគាត់បានដឹងថា ***ខៀវ សំផន*** គឺជាប្រធានគណៈប្រធានរដ្ឋ គឺដោយសារគាត់បានឮពីវិទ្យុ។ នៅពេលបកស្រាយអំពីមូលដ្ឋាននៃជំនឿបែបនេះ គាត់បានពន្យល់ថា លោក ***ខៀវ សំផន*** ហាក់ដូចជាគ្មានអ្វីធ្វើច្រើនទេ ចំណាយពេលភាគច្រើននៅភ្នំពេញ ហើយចាកចេញពីផ្ទះរបស់គាត់មិនញឹកញាប់ជាងលោក **អៀង សារី** ទេ។ លោក **ឡេង ឈឿង** បានទទួលស្គាល់ថា ដោយសារគាត់មិនធ្លាប់ចូលផ្ទះរបស់លោក ***ខៀវ សំផន*** គាត់មិនប្រាកដទេថា លោក ***ខៀវ សំផន*** ធ្វើការនៅផ្ទះឬក៏មិនមែន ហើយមិនដឹងថា គាត់ធ្លាប់រៀបចំកិច្ចប្រជុំជាមួយមេដឹកនាំផ្សេងៗទៀតនៅទីនោះដែរឬទេ។ ពេលសួរថាតើ លោក ***ខៀវ សំផន*** ធ្លាប់ទទួលភ្ញៀវបរទេសពីគណៈប្រតិភូបរទេសដែរឬទេ? លោក **ឡេង ឈឿង** បាននិយាយថា "ប្រហែលម្តង ឬពីរដង។" ព្រះរាជអាជ្ញា **វ៉ាំងសង់ វ៉ាយដ៏ ដេស្មាឯល (Mr. De wilde d'estmael)** បានដាក់សម្ពាធលើសាក្សី ដោយបង្ហាញពីបញ្ជីមួយដែលសរសេរអំពីពិធីជប់លៀងអាហារ ដែល ***ខៀវ សំផន*** ត្រូវបានចោទថា បានចូលរួម រួមទាំងព្រឹត្តិការណ៍មួយនៅក្នុងឆ្នាំ១៩៧៨ ដើម្បីស្វាគមន៍ប្រធានាធិបតីប្រទេស **រូម៉ានី**។ ទោះជាយ៉ាងណា លោក **ឡេង ឈឿង** បានអះអាងថា នៅពេលដែលគាត់បានបម្រើការងារជាអ្នកបើកបរឱ្យជនជាប់ចោទ ***ខៀសវ សំផន*** បានទទួលការអញ្ជើញមកលេងពីរឬបីលើកប៉ុណ្ណោះពីអ្នកការទូត ហើយទទូចថា ដំណើរទស្សនកិច្ចរបស់ប្រធានាធិបតីប្រទេសរូម៉ានី បានកើតឡើងនៅឆ្នាំ១៩៧៧ នៅពេលដែជនជាប់ចោទកំពុងបម្រើការងារនៅ **ក-១២**។ នៅពេលព្រះរាជអាជ្ញាបានបង្ហាញបញ្ជីឈ្មោះប្រទេស ដែលអ្នកការទូតបានទទួលលិខិតពីលោក ***ខៀវ សំផន*** បន្ទាប់មកលោក **ឡេង ឈឿង** បានសារភាពថា គាត់មិនប្រាកដពីចំនួនអ្នកមកជួបលោក ***ខៀវ សំផន*** ជាក់លាក់នោះទេ។

### *ក.៦. ឥរិយាបថ និងភាពគួរឲ្យជឿបាន*

លោក **ឡេង ឈឿង** បានលើកឡើងម្តងហើយម្តងទៀតថា គាត់មានអាយុក្មេង នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលគាត់អាចខ្វះការយល់ដឹង និងខ្វះសមត្ថភាព ក្នុងការចងចាំរឿងរ៉ាវ ដែលបានកើតឡើងទាំងនោះ។ ភាពខុសគ្នាដ៏ធំមួយនៅក្នុងការចងចាំរបស់គាត់ចំពោះព្រឹត្តិការណ៍ទាំងនោះ គឺពាក់ព័ន្ធនឹងកាលបរិច្ឆេទ ដែល **តា មៀល** ត្រូវបានចាប់ខ្លួន និងថាតើសាក្សីមានវត្តមាននៅទីនោះដែរឬទេ ក្នុងអំឡុងពេលនៃការចាប់ខ្លួន។[5] ការរៀបរាប់របស់សាក្សីអំពីសកម្មភាពរបស់លោក ***ខៀវ សំផន*** ក៏មិនត្រូវគ្នានឹងសក្ខីកម្មរបស់សាក្សីដទៃទៀតដែរ។ ទោះបីជា លោក **ឡេង ឈឿង** បានអះអាងថា គាត់គឺជាអ្នកបើកបរតែមួយគត់របស់លោក ***ខៀវ សំផន*** គាត់មិនអាចចងចាំថា តើគាត់បានបើកបរជូនលោក ***ខៀវ សំផន*** ទៅកិច្ចប្រជុំនៅបុរីកីឡា មួយថ្ងៃមុនពេលគាត់ភៀសខ្លួនចេញពីភ្នំពេញ ហើយដែលរឿងរ៉ាវនេះ ត្រូវបានបញ្ជាក់តាមការផ្តល់សក្ខីកម្មរបស់សាក្សីពីរនាក់ផ្សេងទៀត។[6] ម្យ៉ាងទៀត ប្រពន្ធរបស់លោក ***ខៀវ សំផន*** ឈ្មោះ **សូ សុជាតិ** បានផ្តល់សក្ខីកម្មថា កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ឬប្រហាក់ប្រហែលនោះ ***ខៀវ សំផន*** បានទៅយកគាត់ និងកូនពីរនាក់របស់ពួកគាត់ទៅស្ថានីយរថភ្លើង។[7] លោក **ឡេង ឈឿង** បានអះអាងថា គាត់មិនធ្លាប់បើកបរជូន ***ខៀវ សំផន*** ទៅកន្លែងនោះទេ។

## ខ. សក្ខីកម្មរបស់លោក នូ ម៉ៅ (TCW 801)

សាក្សី **នូ ម៉ៅ** បានចូលមកបំភ្លឺក្នុងសវនាការ កាលពីព្រឹកថ្ងៃពុធ ដើម្បីផ្តល់សក្ខីកម្មអំពីបទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហម គោលនយោបាយ និងការរៀបចំផែនការទុកជាមុន សម្រាប់ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ការប្រព្រឹត្តចំពោះព្រះសង្ឃ ទាហាន **លន់ នល់** និងខ្មែរ វៀតមិញ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។[៨] ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី មានការកត់សម្គាល់ថា គាត់មិនធ្លាប់បានការិយាល័យសហចៅក្រមស៊ើបអង្កេតសម្ភាសពីមុននោះទេ ប៉ុន្តែ គាត់ធ្លាប់ត្រូវបានអ្នកសារព័ត៌មាន និងអ្នកប្រវត្តិសាស្ត្រ **ប៊ែន ឃៀរនិន** បានសម្ភាស នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៨១។ ទោះបីជា អង្គជំនុំជម្រះ បានអនុញ្ញាតឱ្យសាក្សីមើលកំណត់ត្រានៃកិច្ចសម្ភាសន៍របស់លោក **ប៊ែន ឃៀរនិន** ក៏ដោយ ក៏ស្ថានភាពសុខភាពមិនល្អរបស់សាក្សី បានប៉ះពាល់ដល់សមត្ថភាពរបស់គាត់ក្នុងការផ្តល់សក្ខីកម្ម ហើយអង្គជំនុំជម្រះ បានផ្អាកជាច្រើនលើកដើម្បីឱ្យសាក្សីសម្រាក។

### *ខ.១. ការជ្រើសរើសឡេចូលបម្រើការក្នុងរបបខ្មែរក្រហម*

លោក **នូ ម៉ៅ** កើតនៅភូមិយុទ្ធ សាមគ្គី ក្នុងស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ហើយបានធ្វើការជាកសិករនៅខេត្តកំពត មុនគាត់បានចូលខ្មែរក្រហមនៅឆ្នាំ១៩៧១។ យោងតាមសាក្សី គោលបំណងនៃបដិវត្តន៍នេះ គឺដើម្បីកៀរគរប្រជាជនប្រឆាំងនឹងរបប **លន់ នល់** ហើយបណ្តេញ "ពួកចក្រពត្តិនិយមអាមេរិក"។ គាត់ត្រូវបានចាត់តាំងជាសមាជិកមួយរូបនៃគណៈកម្មាធិការភូមិ ដែលមានតួនាទីមើលការខុសត្រូវភូមិបី គឺភូមិត្រពាំងធំ ប្រពាំងតឹង និងត្រាំកុល។ បន្ទាប់មក គាត់ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការឃុំនៅជើងរោស។ សាក្សី បានប្រាប់តុលាការ អំពីការរងរបួសដ៏ធ្ងន់ធ្ងររបស់គាត់ បន្ទាប់ពីបានធ្លាក់ពីអង្រឹង ក្នុងអំឡុងពេលនៃការទម្លាក់គ្រាប់បែកនៅភ្នំបាត។ បន្ទាប់ពីរងរបួស នៅពេលជាមួយគ្នានោះដែរ ក៏មានការបង្កើតសហករណ៍ ដើម្បីទទួលអ្នកត្រូវជម្លៀសពីភ្នំពេញ សាក្សីក៏ត្រូវបានទម្លាក់តំណែងឱ្យធ្វើជាសិប្បករវិញ។ សាក្សី ក៏បានអះអាងថា គាត់ត្រូវបានចាប់ខ្លួននៅបាសិត ហើយត្រូវបានបញ្ជូនទៅពន្ធធនាគារខេត្តពោធិ៍សាត់ ប៉ុន្តែ មិនបានបកស្រាយអំពីការជាប់ឃុំឃាំងរបស់គាត់ឡើយ។

### *ខ.២. គោលនយោបាយជម្លៀសប្រជាជន*

លោក **នូ ម៉ៅ** បានចងចាំថា ក្នុងអំឡុងពេលនៃកិច្ចប្រជុំថ្នាក់ឃុំ និងសម័យប្រជុំសិក្សាអំពីគោលនយោបាយ មានការចូលរួមពីថ្នាក់ដឹកនាំរួមមាន **តា ម៉ុក** និង **ជូ ចេត** បានបង្រៀនអំពីផែនការជម្លៀសប្រជាជននៅទីក្រុងភ្នំពេញ។ សាក្សី បានផ្តល់សក្ខីកម្មថា គោលនយោបាយជម្លៀសនេះ ត្រូវបានអនុវត្តរួចទៅហើយនៅតំបន់រំដោះ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ចំពោះបញ្ហានៃការជម្លៀសនេះ គាត់បានចងចាំថា មានការពិភាក្សាជាច្រើននៅតាមឃុំ។ ជាក់ស្តែង សាក្សីបានរម្លឹកអំពីការជម្លៀសនៅស្រុកឧត្តុង្គ និងការជម្លៀសនៅ

ដំណាក់កាលទី២នៅតំបន់ភូមិភាគនិរតី។ សាក្សីបានរៀបរាប់អំពីគោលនយោបាយជម្លៀសថាជា "នយោបាយអត្តឃាត" ដោយខ្មែរក្រហម។ ហើយបន្ថែមថា ការជម្លៀសនេះគឺ "ដើម្បីសម្លាប់" ពីព្រោះដោយសារតែគ្មានអាហារគ្រប់គ្រាន់សម្រាប់ប្រជាជនដែលត្រូវបានជម្លៀស។ ដូចនេះ "ប្រជាជនមូលដ្ឋាន" និង "ប្រជាជនថ្មីៗ" ជាច្រើនបានស្លាប់។

ទោះជាយ៉ាងណា សាក្សីបានបញ្ជាក់យ៉ាងច្បាស់ថា មិនមែនមេដឹកនាំខ្មែរក្រហមទាំងអស់ សុទ្ធតែគាំទ្រការជម្លៀសនៅពេលនោះទេ។ គួរឱ្យកត់សម្គាល់ គាត់បានលើកឡើងថា **ហូ យុន** និង **ជូ ចេត** បានជំទាស់ការជម្លៀសដោយបង្ខំនេះ ចំណែកឯ **តា ម៉ុក** វិញ គឺជាអ្នកគាំទ្រយ៉ាងខ្លាំងលើគោលនយោបាយជម្លៀសនេះ។ ដើម្បីអះអាងពីសក្ខីកម្មរបស់គាត់ សាក្សីបានលើកឡើងអំពីកិច្ចប្រជុំមួយចំនួន ដែលគាត់បានចូលរួម នៅពេលដែលមេដឹកនាំ បានបង្ហាញអំពីទស្សនៈរបស់ពួកគាត់មកលើគោលនយោបាយជម្លៀសនេះ។ លោក **ហូ យុន** បានប្រកាន់ជំហរលើគោលនយោបាយនេះយ៉ាងច្បាស់ក្នុងកិច្ចប្រជុំមួយនៅវត្ត **តាំង ហ្វូ** នៅក្នុងពេលមួយនៅចន្លោះឆ្នាំ ១៩៧២ និងឆ្នាំ១៩៧៣។ ក្នុងអំឡុងសម័យប្រជុំសិក្សា ដែលលោក **នូ ម៉ៅ** ចូលរួមសិក្សានៅពេលមួយក្នុងឆ្នាំ ១៩៧៣ គាត់ក៏បានរម្លឹកថា **តា ម៉ុក** និង **ជូ ចេត** បានបង្ហាញពីទស្សនៈប្រឆាំងគ្នាទាក់ទងនឹងផែនការជម្លៀសនេះ។ **តា ម៉ុក** បានទទូចឱ្យជម្លៀសអ្នកគ្រប់គ្នានៅក្នុងទីក្រុង ចំណែកឯ **ជូ ចេត** មិនបានឯកភាពអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះទេ។ ទាក់ទងនឹងការគាំទ្ររបស់លោក **ខៀវ សំផន** លើគោលនយោបាយជម្លៀសនេះ សាក្សីបានផ្តល់សក្ខីកម្ម ដែលវាមិនស្របគ្នានឹងកំណត់ត្រានៃកិច្ចសម្ភាសន៍របស់លោក **ប៉ែន យៀរនិន** បានធ្វើឡើយ។ កំណត់ត្រានៃកិច្ចសម្ភាសនេះ បានកត់ត្រាអំពីគាត់និយាយប្រាប់លោក **ប៉ែន យៀរនិន** ថាគាត់បានដឹងអំពីការគាំទ្ររបស់លោក **ខៀវ សំផន** ពីមេដឹកនាំយោធាឈ្មោះ **ម៉ាត**។ ទោះជាយ៉ាងណា ក្រោមការសាកសួររបស់មេធាវីការពារក្តី សាក្សីបានបញ្ជាក់ថា គាត់មិនធ្លាប់ស្គាល់លោក **ខៀវ សំផន** ហើយក៏មិនដឹងថាគាត់គាំទ្រគោលនយោបាយនេះដែរឬទេ។

### ***ខ.៣. វគ្គសិក្សារៀនសូត្រ***

សាក្សី ក៏បានរម្លឹកអំពីការចូលរួមក្នុងវគ្គសិក្សារៀនសូត្រមួយចំនួននៅឃុំកន្ទួត ស្រុកត្បូង ជាមួយកម្មាភិបាលជាន់ទាបផ្សេងៗទៀតមកពីឃុំ ស្រុក និងថ្នាក់តំបន់។ សាក្សី មិនអាចចងចាំអំពីកាលបរិច្ឆេទឲ្យពិតប្រាកដនៃវគ្គសិក្សារៀនសូត្រនោះទេ ប៉ុន្តែកំណត់ត្រាកិច្ចសម្ភាសន៍របស់លោក **ប៉ែន យៀរនិន** បានដកស្រង់ថា វគ្គសិក្សារៀនសូត្រ គឺនៅឆ្នាំ១៩៧៣។ នៅពេលនោះ **ជូ ចេត** ហៅ "**ស៊ី**" បានបង្រៀនអំពីកិច្ចការនយោបាយ ចំណែកឯ **តា ម៉ុក** បានបង្ហាញអំពីកិច្ចការយោធា។ លោក **នូ ម៉ៅ** បានពន្យល់នៅមុខអង្គជំនុំជម្រះថា ក្នុងអំឡុងពេលវគ្គសិក្សារៀនសូត្រ ដែលគាត់បានចូលរួមនោះថា អ្នកចូលរួមទាំងអស់ ត្រូវសរសេរអំពីជីវប្រវត្តិរបស់ខ្លួន និងត្រូវបានលើកទឹកចិត្តឱ្យជ្រើសរើសអ្នកផ្សេងទៀត ឲ្យចូលរួមក្នុងចលនាតស៊ូនេះ។

### *ខ.៤. ការប្រព្រឹត្តចំពោះកងកម្លាំងខ្មែរ វៀតមិញ*

ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី គាត់បានពន្យល់អំពីតួនាទីរបស់ខ្មែរ វៀតមិញ ក្នុងអំឡុងពេលបដិវត្តន៍ និងការប្រព្រឹត្តទៅលើពួកគេជាបន្តបន្ទាប់ក្រោយឆ្នាំ១៩៧៤។ ក្រុមអ្នកតស៊ូប្រមាណ ២,០០០ ទៅ ៣,០០០ នាក់ ដែលគេដឹងថាជាកម្លាំងខ្មែរ វៀតមិញ ដែលត្រូវបានបញ្ជូនពីវៀតណាម ដើម្បីដើរតួនាទីជាអ្នកផ្តល់ប្រឹក្សាលើកិច្ចការយោធា និងវប្បធម៌។ ទោះបីជាមានការយល់ច្រឡំជាមួយនឹងការប្រើប្រាស់ឆ្លាស់គ្នារវាងពាក្យ "ខ្មែរ វៀតមិញ" និង "ខ្មែរហាណូយ" តែព្រះរាជអាជ្ញា **រេយ័ន័រ** បានបញ្ជាក់ថា "ខ្មែរ វៀតមិញ" សំដៅលើក្រុមអ្នកតស៊ូខ្មែរ ដែលត្រឡប់មកវិញពីប្រទេសវៀតណាម ដើម្បីប្រយុទ្ធប្រឆាំងនឹងរបប **លន់ នល់** បន្ទាប់ពីទទួលបានការអប់រំនៅវៀតណាម។ សាក្សី បានប្រាប់តុលាការថា នៅពេលមួយក្នុងអំឡុងឆ្នាំ១៩៧៤ ឃើញមានកងកម្លាំងខ្មែរវៀតមិញ រាប់ពាន់នាក់ បានប្រមូលផ្តុំគ្នា ដែលបានធ្វើឡើងដោយ "ថ្នាក់លើ" របស់ខ្មែរក្រហម ហើយអ្នកដែលមកចូលរួមទាំងនោះ ត្រូវបានបញ្ជូនទៅអប់រំឡើងវិញ បន្ទាប់មកក៏បាត់ខ្លួន និងមិនបានបង្ហាញខ្លួនម្តងទៀតឡើយ។ សាក្សី បានជឿជាក់ថា មនុស្សទាំងនោះបានស្លាប់ ទោះបីជាគាត់មិនបានបកស្រាយលម្អិតបន្ថែមអំពីជំនឿរបស់គាត់ក៏ដោយ។

### *ខ.៥. ការប្រព្រឹត្តចំពោះព្រះសង្ឃ*

លោក **នូ ម៉ៅ** ក៏ត្រូវបានសាកសួរពាក់ព័ន្ធនឹងយុទ្ធនាការផ្សឹកព្រះសង្ឃ។ បន្ទាប់ពីមើលកំណត់ត្រានៃកិច្ចសម្ភាសន៍របស់គាត់ដោយលោក **ប៉ែន យៀរនិន** ក្នុងឆ្នាំ១៩៨១ សាក្សីបានរម្លឹកថា **តា ម៉ុក** បានរៀបចំកិច្ចប្រជុំក្នុងខេត្តកំពង់ឆ្នាំង ដែលធ្វើឡើងក្នុងគោលបំណងទាក់ទាញព្រះសង្ឃឱ្យសឹក ហើយចូលរួមបម្រើកងទ័ព។ ទោះជាយ៉ាងណា សាក្សីមិនអាចចងចាំ ថាតើមានព្រះសង្ឃប៉ុន្មានអង្គ បានចូលរួមក្នុងកងទ័ពនោះទេ បន្ទាប់ពីកិច្ចប្រជុំនោះបានធ្វើឡើង។ លោក **នូ ម៉ៅ** បានអះអាងថា គ្មានព្រះសង្ឃសម្រាប់ផ្សឹកទៀតទេ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលមួយក្នុងអំឡុងពេលផ្តល់សក្ខីកម្មនោះ ប៉ុន្តែ គាត់បានសារភាពថា គាត់មិនបានដឹងដោយផ្ទាល់អំពីស្ថានភាពនៅទីក្រុងភ្នំពេញទេ។

### *ខ.៦. ការប្រព្រឹត្តចំពោះទាហាន លន់ នល់*

ពាក់ព័ន្ធនឹងការបាត់ខ្លួនរបស់ទាហាន **លន់ នល់** បន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សាក្សីបានលើកឡើងថា គាត់ឃើញទាហាន និងជនស៊ីវិលដែលភៀសខ្លួន បានមកដល់ឃុំ **ជើងរោស**។ លោក **នូ ម៉ៅ** បានរម្លឹកថា ទាហាន **លន់ នល់** គ្មានប្រដាប់អាវុធប្រមាណជា ១០០ នាក់ ត្រូវបានបំបែកពីជនស៊ីវិល ហើយត្រូវបានបញ្ជូនទៅភាគខាងត្បូងនៃវត្តព្រៃជ្រំ។ ទាហាន ដែលបានចាកចេញទៅហើយ ក៏លែងឃើញត្រឡប់មកវិញ ហើយគាត់បានដឹងបញ្ហានេះពីអ្នកដទៃថា អង្គការបានបញ្ជូនទាហានទាំងនោះទៅអប់រំម្តងសាឡើងវិញ។ សាក្សីបាននិយាយថា គាត់បានជឿថា ទាហានទាំងនោះត្រូវបានសម្លាប់ហើយ។ ប៉ុន្តែលោក **កូប៉េ** ដេញដោល

ត្រង់ចំណុចថា ទាហានទាំងនោះ ត្រូវបានសម្លាប់ វាគឺជាការ "ការប៉ាន់ស្មាន" របស់សាក្សីតែប៉ុណ្ណោះ។ឃើញដូចនេះ លោក **នូ ម៉ៅ** បានឆ្លើយតបភ្លាមៗថា "អ្នកអាចនិយាយថា ខ្ញុំប៉ាន់ស្មានក៏បាន ឬក៏និយាយថា ខ្ញុំប្រាប់អ្នកអំពីការពិតក៏បាន ពីព្រោះពួកគេមិនបានត្រឡប់មកវិញទេ"។[9]

### *ខ.៧. ឥរិយាបថ និងភាពអាចជឿទុកចិត្តបានរបស់សាក្សី*

សាក្សី ហាក់ដូចជានឿយហត់ និងកាន់តែមិនស្រួលខ្លួនខ្លាំងឡើងៗ នៅពេលដែលការផ្តល់សក្ខីកម្មរបស់គាត់ចេះតែបានបន្តទៅមុខ។ អង្គជំនុំជម្រះ បានផ្អាកការផ្តល់សក្ខីកម្មរបស់គាត់មុនពេលកំណត់ជាច្រើនលើកដោយសារសាក្សីមើលទៅ ពិតជាគ្មានកម្លាំងនឹងអាចបន្តផ្តល់សក្ខីកម្មទៀតបានឡើយ។ ឧទាហរណ៍ នៅចុងបញ្ចប់នៃការផ្តល់សក្ខីកម្មរបស់គាត់នៅថ្ងៃពុធ មានការមើលឃើញច្បាស់ថា គាត់មានការលំបាកក្នុងការផ្តោតយកចិត្តទុកដាក់ និងតាមដានសំណួរពីក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា**។ ក្រៅពីការកត់សម្គាល់បញ្ហាសុខភាពរបស់សាក្សីហើយ ក៏ឃើញថាលោក **នូ ម៉ៅ** បានជៀសវាងចម្លើយដែលជាការប៉ាន់ស្មាន ហើយបានបន្តរម្លឹកដល់អង្គជំនុំជម្រះថា ព្រឹត្តិការណ៍ទាំងនោះបានកើតឡើងអស់រយៈពេលយូរមកហើយ ហើយការចងចាំរបស់គាត់នៅមានកម្រិត។ ទោះជាយ៉ាងណា ក្រុមការងារឃ្លាំងមើលតាមដានសវនាការ បានកត់សម្គាល់អំពីភាពខុសប្លែកផ្សេងគ្នាដ៏សំខាន់ៗរវាងសក្ខីកម្មរបស់សាក្សី និងកំណត់ត្រាបទសម្ភាសន៍របស់លោក **ប៉ែន យៀរនិន** ចុះឆ្នាំ១៩៨១ ជាពិសេសទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ **ខៀវ សំផន** (មើលផ្នែក ខ.២.)។ មុននឹងបញ្ចប់នៃសក្ខីកម្មរបស់សាក្សី អង្គជំនុំជម្រះ បានឯកភាពជាមួយអយ្យការ និងក្រុមមេធាវីការពារក្តីថា ត្រូវធ្វើការត្រួតពិនិត្យប្រតិចារឹកយ៉ាងយកចិត្តទុកដាក់ នៅពេលថ្លឹងថ្លែងអំពីសក្ខីកម្ម ដោយសារតែមានភាពផ្ទុយគ្នា ដែលបានកើតឡើងនេះ។ នេះប្រហែលជាបណ្តាលមកពីបញ្ហាសុខភាពរបស់គាត់ផងដែរ ទើបចម្លើយរបស់សាក្សី ជាញឹកញាប់ចាកប្រធាន ហើយបានធ្វើឱ្យអង្គជំនុំជម្រះ បានរម្លឹកដល់សាក្សីឱ្យផ្តល់ចម្លើយដែលពាក់ព័ន្ធ និងខ្លី ហើយច្បាស់។

## ផ្នែកទី ៣ ៖ បញ្ហាផ្លូវច្បាប់ និងនីតិវិធី

បញ្ហាផ្លូវច្បាប់ និងនីតិវិធីនៅសប្តាហ៍នេះ ផ្តោតលើដំណើរការនីតិវិធីសាកសួរលើសាក្សី ហើយនិងការជំទាស់មួយចំនួនទាក់ទងទៅនឹងចម្លើយនៃការប៉ាន់ស្មាន និងការសួរសំណួរដដែលៗ។ ព្រះរាជអាជ្ញា ក៏បានស្នើឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរនៅត្រឹមកម្រិតមួយ ត្រឹមតែការទទួលរងទុក្ខសោករបស់កូនក្តីរបស់ខ្លួនបានហើយ។ ការពិភាក្សាសួរដេញដោល បានអូសបន្លាយច្រើនទាក់ទងនឹងការប្រើប្រាស់កំណត់ត្រាបទសម្ភាសន៍របស់លោក **ប៉ែន យៀរនិន** ក្នុងអំឡុងពេលសាកសួរសាក្សី **នូ ម៉ៅ** ហើយជាពិសេស ដោយសារតែបទសម្ភាសន៍នេះ មិនមែនជាសម្អាងហេតុ ហើយមិនបានធ្វើសច្ចាប្រណិធាន និងមិនមានភាពច្បាស់លាស់ថាតើសាក្សីនោះមានឱកាសបានផ្ទៀងផ្ទាត់កំណត់ត្រា ដែលលោក **ប៉ែន យៀរនិន** បានធ្វើឡើងឬទេ។ ជាទីបញ្ចប់ អង្គជំនុំជម្រះអនុញ្ញាតឱ្យសាក្សីមើលកំណត់ត្រានោះ ប៉ុន្តែ បានរម្លឹកដល់អយ្យការថា ឯកសារនោះ មិនមែនសម្រាប់ប្រើប្រាស់

ដូចសម្អាងហេតុ ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតបានឡើយ ដោយសារតែមានភាពខុសគ្នា នៃការធ្វើសច្ចាប្រណិធាន។

### ក. ដីកាសាកសួរសាក្សី

កាលពីថ្ងៃចន្ទ បន្ទាប់ពីលោកប្រធាន **និល ណុន** បានបញ្ជាក់អំពីអត្តសញ្ញាណរបស់សាក្សី **ឡេង ឈឿង** ហើយនិងបានកំណត់អំពីនីតិវិធីសួរដេញដោលទៅតាមលំដាប់លំដោយមុនក្រោយសម្រាប់ភាគីនីមួយៗ។ យ៉ាងណាមិញ ក្រុមមេធាវីការពារក្ដីឲ្យជនជាប់ចោទ **ខៀវ សំផន** គឺអ្នកស្រី **អង់តាហ្គីសេ** បានស្នើលោក **ឡេង ឈឿង** ធ្វើជាសាក្សី ប៉ុន្តែ អ្នកស្រីបានស្នើដោយយោងទៅតាមអនុស្សរណៈ ដែលបានធ្វើឡើងដោយអង្គជំនុំជម្រះ សូមឲ្យការិយាល័យសហព្រះរាជអាជ្ញា គួរជាអ្នកចាប់ផ្ដើមសាកសួរសាក្សីមុន។ ព្រះរាជអាជ្ញា **វ៉ាំសង់វ៉ាយដ៍ ដេស្មាឯល** បានឆ្លើយតបថា អង្គជំនុំជម្រះគួរតែអនុវត្តតាម "ទម្លាប់អនុវត្តដែលបានបង្កើតឡើង" ហើយតម្រូវឱ្យភាគីដែលហៅសាក្សី ចាប់ផ្ដើមធ្វើការសាកសួរមុន។[10] យោងតាមការអះអាងរបស់អ្នកស្រី **ហ្គីសសេ** ថា ដោយសារតែសាក្សី គឺមានក្នុងបញ្ជីឈ្មោះសាក្សី ដែលការិយាល័យសហព្រះរាជអាជ្ញាបានស្នើឡើង ហើយការផ្ដល់សក្ខីកម្មរបស់សាក្សីរូបនេះ ក៏មិនពាក់ព័ន្ធនឹងសំណើរបស់ជនជាប់ចោទ។ ដូចច្នេះ ការិយាល័យសហព្រះរាជអាជ្ញា គួរតែចាប់ផ្ដើមសាកសួរសាក្សីមុន។ លោកប្រធាន **និល ណុន** បានសម្រេចថា អ្វីដែលសំខាន់នោះ សាក្សីរូបនេះ គឺជាសាក្សីរបស់ក្រុមមេធាវីការពារក្ដី។ ដូច្នេះហើយ ក្រុមមេធាវីការពារក្ដីគួរតែចាប់ផ្ដើមសាកសួរមុន ទោះបីជាមានការកំណត់នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះក៏ដោយ។

### ខ. ការប៉ាន់ស្មាន និងវិសាលភាពនៃចំណេះដឹងរបស់សាក្សី

កម្រិតដែលសាក្សីត្រូវបានអនុញ្ញាតឱ្យផ្ដល់ការប៉ាន់ស្មាន ឬមតិយោបល់ ហាក់ដូចជាស្ថិតនៅក្នុងឆន្ទានុសិទ្ធិទាំងស្រុងរបស់អង្គជំនុំជម្រះ ពេញមួយសប្ដាហ៍នោះ។ កាលពីថ្ងៃចន្ទ លោកប្រធានបានគាំទ្រការជំទាស់ពីក្រុមមេធាវីការពារក្ដី ហើយបានព្រមានព្រះរាជអាជ្ញា ឲ្យជៀសវាងស្នើឲ្យសាក្សី **ឡេង ឈឿង** "ធ្វើការបង្ហាញចេញពីការអង្កេតឃើញផ្ទាល់របស់សាក្សី" បន្ទាប់ពីព្រះរាជអាជ្ញា **ចាន់ តារាស្មី** បានសួរសាក្សីឲ្យរៀបរាប់អំពីភាពលំបាករបស់ប្រជាជននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ កាលពីថ្ងៃពុធ ដោយគ្មានការសម្រេចពីអង្គជំនុំជម្រះ ព្រះរាជអាជ្ញា បានឯកភាពប្ដូរសំណួររបស់ខ្លួន បន្ទាប់ពីមេធាវីការពារក្ដី បានជំទាស់ថា ព្រះរាជអាជ្ញា បានស្នើឱ្យសាក្សី **នូ ម៉ៅ** ឆ្លើយតបនឹងសំណួរ ដោយមិនបានបង្ហាញពីប្រភពនៃព័ត៌មាននោះ។ ក្នុងអំឡុងពេលសួរដេញដោលរបស់មេធាវីការពារក្ដីទៅលោក **នូ ម៉ៅ** ឃើញថា ចៅក្រម **និល ណុន** បានច្រានចោលការជំទាស់មួយដែលធ្វើឡើងដោយព្រះរាជអាជ្ញា **វេយ័ន័រ** ទាក់ទងនឹងសំណួរមួយ ដែលស្នើឱ្យសាក្សី ផ្ដល់មតិអំពីជំហររបស់មេដឹកនាំខ្មែរក្រហម ទាក់ទងនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ ដោយព្រះរាជអាជ្ញាបានលើកឡើងថា "មិនសមរម្យ" ឬ "គ្មានមូលដ្ឋានត្រឹមត្រូវ"។ ព្រះរាជអាជ្ញា **វេយ័ន័រ** បានអះអាងថា សំណួររបស់លោក **កូប៉េ** អាចឱ្យមាន "ការប៉ាន់ស្មានកម្រិតខ្ពស់បំផុត" ដោយសារសំណួរនេះ សួរឱ្យសាក្សីនិយាយអំពីអ្វីដែលអាចកើតឡើងរវាង **ជួ ចេត** និង

**តា ម៉ុក**។ លោក **កូប៉េ** បានការពារចំពោះសំណួរដែលលោកបានសាកសួរ ដោយបង្ហាញថា គាត់បានព្យាយាម បង្ហាញពីភាពផ្ទុយគ្នាពីសាក្សី ដោយលើកឡើងអំពីការសួរដេញដោលរបស់អយ្យការលើ អ្នកស្រី **សូ សុជាតិ** កាលពីសប្តាហ៍មុន ដើម្បីគាំទ្រវិធីសាស្ត្រសាកសួររបស់គាត់។[11]

## គ. ការសាកសួរដដែលៗ និងការប្រឈមទៅនឹងសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

បញ្ហាទាក់ទងនឹងការសួរសំណួរដដែលៗ ត្រូវបានលើកឡើងជាច្រើនដងក្នុងអំឡុងពេលសប្តាហ៍នោះ។ លោក **វេយ័ន័រ** បានលើកពីបញ្ហាមួយចំនួនទាក់ទងនឹងសំណួរ ដែលចោទសួរដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលគាត់ចាត់ទុកថា មានលក្ខណៈដដែលៗ ហើយក៏បានអះអាងផងដែរថា សំណួរមួយចំនួន ដែលបានចោទសួរ គឺហួសពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងអំឡុងពេលសាកសួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទៅលើសាក្សី **នូ ម៉ៅ** វាបានឃើញថា ព្រះរាជអាជ្ញា បានជំទាស់ពីវិធីសាកសួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដោយអះអាងថា មេធាវីបានសួរសំណួរដែលពីមុន ព្រះរាជអាជ្ញាបានសួរមកហើយ ដូច្នេះ ការសួរសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺធ្វើឡើងហួសពីតួនាទីហើយ។[12] សហមេធាវីជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី គឺ លោក **ពេជ អង្គ** បានទទួលស្គាល់ថា សំណួរមួយចំនួនហាក់ដូចជាដដែលៗ ប៉ុន្តែ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតឱ្យសួរសាក្សីទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ហើយក៏មិនគួរមានការរឹតបន្តឹងក្នុងការសួរសំណួរ អំពីការទុក្ខសោករបស់ជនរងគ្រោះឡើយ។ ប្រធានចៅក្រម **និល ណុន** បានណែនាំដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឲ្យជៀសវាងសួរសំណួរដដែលៗ ហើយបានលើកឡើងថា អង្គជំនុំជម្រះនឹងពិចារណាអំពីភាពពាក់ព័ន្ធនៃសំណួរក្រោយៗ។ ភ្ជាប់ទៅនឹងការសម្រេចបន្ថែ អង្គជំនុំជម្រះ ក៏បានស្នើឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **បេនី យេ** (Mrs. Beini Ye) ឲ្យបន្តទៅលើប្រធានបទថ្មីមួយទៀត នៅពេលលោកស្រី ព្យាយាមសាកសួរសំណួរទាក់ទងនឹងការសម្លាប់ទាហាន **លន់ នល់**។ លោកប្រធាន ក៏បានស្នើឲ្យមេធាវីការពារក្តី **សុន អរុណ** ឲ្យបន្តប្រធានបទមួយទៀត បន្ទាប់ពីព្រះរាជអាជ្ញា **វេយ័ន័រ** បានធ្វើការជំទាស់ ដោយអះអាងថា សំណួររបស់មេធាវីការពារក្តីគឺ "ដដែលៗពេក"។[13]

## ឃ. ការប្រើប្រាស់កំណត់ត្រាបទសម្ភាសន៍របស់លោក ប៉ែន យៀវនិន ដើម្បីសាកសួរសាក្សី

កាលពីព្រឹកថ្ងៃពុធ អង្គជំនុំជម្រះ បានច្រានចោលការជំទាស់របស់មេធាវីការពារក្តី ក្នុងអំឡុងពេលនៃការសាកសួររបស់ព្រះរាជអាជ្ញា ហើយអនុញ្ញាតឲ្យព្រះរាជអាជ្ញា ប្រើប្រាស់កំណត់ត្រានៃកិច្ចសម្ភាសន៍ដែលសរសេរដោយដៃ ដែលបានធ្វើឡើងដោយ **ប៉ែន យៀវនិន** ជាមួយសាក្សី **នូ ម៉ៅ** កាលពី ៣១ ឆ្នាំមុន។ អ្នកស្រី **ហ្គីសសេ** បានជំទាស់ការប្រើប្រាស់កំណត់ត្រានោះ ហើយបានអះអាងថា លោក **វេយ័ន័រ** មិនបានផ្តល់មូលដ្ឋានគ្រប់គ្រាន់សម្រាប់កំណត់ហេតុនោះទេ ជាពិសេស ថាតើសាក្សីបានអានកំណត់ហេតុនោះហើយឬនៅ ដើម្បីបញ្ជាក់ពីភាពពិតប្រាកដនៃកំណត់ហេតុទាំងនោះ។ គាត់បានរម្លឹកដល់អង្គជំនុំជម្រះថា វិធីតែមួយគត់ ដើម្បីស្វែងរកការពិតគឺត្រូវសួរសាក្សី ពីព្រោះ លោក **ប៉ែន យៀវនិន** បានបដិសេធមិនផ្តល់សក្ខីកម្មមុខអង្គជំនុំជម្រះ។[14] លោក **កូប៉េ** ក៏

បានជជែកដែរថា ដោយសារតែឯកសារដើមជាភាសាអង់គ្លេស ហើយលោក **នូ ម៉ៅ** ទាំងអាន និងនិយាយ សុទ្ធតែជាភាសាខ្មែរ រីឯកសារវិញនោះ មិនអាចជាជំនួយដល់សាក្សីបាននោះទេ។ គាត់ក៏បានសួរដែរថា តើឯកសារនោះពិតជាឆ្លុះបញ្ចាំងពីពាក្យពេចន៍ផ្ទាល់របស់លោក **នូ ម៉ៅ** តាំងពី ៣១ ឆ្នាំមុន បានយ៉ាងត្រឹមត្រូវដែរឬទេ។

ជាការឆ្លើយតប លោក **វេយ័ន័រ** បានអះអាងថា ការប្រើប្រាស់ឯកសារនេះ គឺសមហេតុផល ដោយសារការចងចាំចុះខ្សោយ និងសុខភាពទន់ខ្សោយរបស់លោក **នូ ម៉ៅ** ក៏ដូចជារយៈពេលដែលព្រឹត្តិការណ៍នោះបានកើតឡើងយូរហើយ។ គាត់ក៏បានលើកឡើងពីសាក្សីមុនៗ ដែលបានទទួលការអនុញ្ញាតឱ្យមើលឯកសារ ដើម្បីជួយការចងចាំរបស់ពួកគាត់។ ក្នុងការឆ្លើយតបនឹងការជំទាស់របស់មេធាវីការពារក្តី លោក **វេយ័ន័រ** បានអះអាងថា កិច្ចសម្ភាសន៍នោះ ត្រូវបានចាត់ទុកថា អាចទទួលយកបាន ហើយអំណះអំណាងរបស់មេធាវីការពារក្តី គឺគ្រាន់តែពាក់ព័ន្ធនឹងភស្តុតាងបញ្ជាក់ប៉ុណ្ណោះ។[15] បន្ទាប់ពីការពិចារណាយ៉ាងហ្មត់ចត់ជាមួយចៅក្រមផ្សេងទៀត លោក**និល ណុន** បានរម្លឹកដល់ភាគីនានា អំពីភាពខុសគ្នារវាងកំណត់ហេតុ និងអំណះអំណាងរបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលត្រូវបានធ្វើឡើយដោយសច្ចាប្រណិធាន។ ទោះបីជាអង្គជំនុំជម្រះ បានអនុញ្ញាតឱ្យភាគីនានាប្រើប្រាស់កំណត់ហេតុក្នុងអំឡុងពេលសាកសួរក៏ដោយ ក៏អង្គជំនុំជម្រះ បានគាំទ្រការជំទាស់មួយចំនួនពីក្រុមមេធាវីការពារក្តី ទាក់ទងនឹងការប្រើប្រាស់កំណត់ហេតុដោយព្រះរាជអាជ្ញា ដោយក្រើនរម្លឹកដល់លោក កុំឲ្យព្យាយាមពឹងផ្អែកលើកំណត់ហេតុពេក ពីព្រោះ វាមិនដូចជាកំណត់ត្រានៃកិច្ចសម្ភាសន៍ ដែលបានធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញាស៊ើបអង្កេតទេ។[16]

### ង. សេចក្តីសម្រេចលើនីតិវិធីដោយអង្គជំនុំជម្រះ ក្នុងការដាក់កំហិតលើការជំទាស់តបវិញរបស់ភាគី

មុននឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវបានធ្វើឡើង ចំពោះការប្រើប្រាស់កំណត់ហេតុរបស់លោក **ប៉ែន យៀរនិន** ចៅក្រម **ស៊ីលវៀ ខាតរ៉ាយថ៍** (Mrs. Silvia Cartwright) បានប្រាប់ដល់ភាគីទាំងអស់អំពី "បញ្ហាដំណើរការនៃនីតិវិធី"។ លោកស្រីចៅក្រម បានលើកឡើងថា អង្គជំនុំជម្រះ នឹងមិនស្តាប់ទទ្បីករណ៍បន្ទាប់បន្សំពីភាគីណាឡើយ បើការជំទាស់នេះ ត្រូវបានឆ្លើយតបធ្វើឡើងម្តងរួចហើយ។ ការសម្រេចចំពោះនីតិវិធីដោយអង្គជំនុំជម្រះ ត្រូវបានធ្វើឡើង ដោយសារតែលោកស្រីមេធាវីការពារក្តី **ហ្គីសសេ** ព្យាយាមធ្វើការជំទាស់ជាលើកទីពីរទៅអង្គជំនុំជម្រះ បន្ទាប់ពីព្រះរាជអាជ្ញា **វេយ័ន័រ** បានឆ្លើយតបនឹងការជំទាស់របស់អ្នកស្រីម្តងរួចមក។

### ច. វិធាន ៨៧ នៃវិធានផ្ទៃក្នុង ការដាក់សំណើដើម្បីទទួលភស្តុតាងថ្មី

នៅថ្ងៃពុធព្រឹក ព្រះរាជអាជ្ញា **វេយ័ន័រ** បានសួរសាក្សី **នូ ម៉ៅ** អំពីរូបថតមួយសន្លឹករបស់លោក **ប៉ែន យៀរនិន** ដែលព្រះរាជអាជ្ញាបានទទួលពីអង្គភាពគាំទ្រសាក្សី និងអ្នកជំនាញ (WESU) មុនពេលការផ្តល់សក្ខីកម្មរបស់លោក **នូ ម៉ៅ**។ បន្ទាប់ពីបង្ហាញរូបថតហើយ សាក្សីបានពន្យល់អំពីរបៀបដែលគាត់មានរូបថតនោះ ដូច្នេះ លោក **វេយ័ន័រ** បានស្នើឲ្យទទួលស្គាល់នៅរូបថតនោះ ធ្វើជាភស្តុតាង ដោយយោងតាមវិធាន ៨៧ នៃវិធាន

ផ្ទៃក្នុងនៃ **អ.វ.ត.ក**។[17] ព្រះរាជអាជ្ញា បានធ្វើយុត្តិកម្មលើការដាក់រូបថតនោះ ជាភស្តុតាងថ្មីនៅដំណាក់កាលបើកសវនាការ ពីព្រោះពាក់ព័ន្ធនឹងការធានារកការពិត ហើយ "ជាក់ស្តែង" ការិយាល័យសហព្រះរាជអាជ្ញាទើបតែដឹងអំពីអត្ថិភាពរបស់វា នៅពេលសាក្សីបានបង្ហាញវា។ វាហាក់បីដូចជាមានការភ្ញាក់ផ្អើលពីសំណាក់មេធាវីការពារក្តីចំពោះ ការអនុវត្តន៍របស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការផ្តល់រូបថតឲ្យសាក្សី ធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ពួកគេ។ យ៉ាងណាវិញ អង្គជំនុំជម្រះ បានបញ្ជាឱ្យទទួលយករូបថតនោះដាក់ចូលក្នុងឯកសារសំណុំរឿង ហើយប្រាប់មេធាវីការពារក្តីថា ពួកគាត់អាចដាក់សំណើតវ៉ាបញ្ហានេះ នៅពេលក្រោយទៀតបាន។

## ផ្នែកទី ៤ ៖ ការគ្រប់គ្រងសវនាការ

នៅសប្តាហ៍នេះ អង្គជំនុំជម្រះ បានបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សីពីររូប។ ដោយសារតែនៅថ្ងៃអង្គារ ជាថ្ងៃបុណ្យជាតិ តុលាការបានបន្តការស្តាប់សក្ខីកម្ម តែបីថ្ងៃប៉ុណ្ណោះនៅសប្តាហ៍នេះ។ ដោយសារតែមិនមានបញ្ហាកើតឡើង ទាក់ទងទៅនឹងសម្ភារប្រើប្រាស់ បំពាក់នៅក្នុងបន្ទប់តុលាការ។ ដូច្នេះ សវនាការសប្តាហ៍នេះត្រូវបានបញ្ចប់យ៉ាងរលូន។

### ក. វត្តមាន

ជនជាប់ចោទ **នួន ជា** នៅបន្តក្នុងបន្ទប់ឃុំឃាំង ដោយសារបញ្ហាសុខភាពរបស់គាត់ ចំណែកឯជនជាប់ចោទ **ខៀវ សំផន** វិញ បានមកតាមដានដំណើរការនីតិវិធីសវនាការដោយផ្ទាល់នៅក្នុងបន្ទប់តុលាការ ពេញមួយសប្តាហ៍នេះ។

វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖ ដើមបណ្តឹងរដ្ឋប្បវេណីប្រមាណពី១៥ ទៅ ២០ នាក់ បានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីជារៀងរាល់ថ្ងៃ ទាំងនៅក្នុងបន្ទប់តុលាការ និងនៅក្នុងសាលសវនាការសាធារណៈ។

វត្តមានរបស់ភាគីផ្សេងៗ៖ ភាគីទាំងអស់ មានការតំណាងយ៉ាងល្អពីមេធាវីនៅក្នុងសប្តាហ៍នោះ។

វត្តមានរបស់សាធារណជន៖

| កាលបរិច្ឆេទ | ពេលព្រឹក | ពេលរសៀល |
|---|---|---|
| ថ្ងៃចន្ទ ១៧/៦/២០១៣ | • សមាគមយុវជនរាជរដ្ឋាភិបាលចំនួន ៣៥០ មកពីសង្កាត់ចំនួន ៨ នៅទីក្រុងភ្នំពេញ (ពាក្យ "សង្កាត់" ស្មើនឹង "ឃុំ" នៅថ្នាក់ខេត្ត)។<br>• អ្នកអង្កេតការណ៍បរទេស ១ រូប | • សមាគមយុវជនរាជរដ្ឋាភិបាលចំនួន ៣៥០ មកពីសង្កាត់ចំនួន ៨ នៅទីក្រុងភ្នំពេញ<br>• ជនបរទេស ៥ នាក់ |
| ថ្ងៃពុធ | • សមាគមយុវជនរាជរដ្ឋាភិបាលចំនួន | • សមាគមយុវជនរាជរដ្ឋាភិបាលចំនួន |

| | | |
|---|---|---|
| ១៩/៦/២០១៣ | ១០០ មកពីខណ្ឌឫស្សីកែវ ភ្នំពេញ<br>• អ្នកសង្កេតការណ៍បរទេស ០៤ រូប | ១០០ មកពីខណ្ឌឫស្សីកែវ ភ្នំពេញ<br>• អ្នកអង្កេតការណ៍បរទេស ៣ រូប |
| ថ្ងៃព្រហស្បតិ៍ ២០/៦/២០១៣ | • សិស្សវិទ្យាល័យបាក់ទូកចំនួន ៣០០ នាក់ នៅភ្នំពេញ<br>• អ្នកសង្កេតការណ៍បរទេស ១២ រូប | • សិស្សចំនួន ២០០ នាក់មកពីវិទ្យាល័យខុសៗគ្នានៅទីក្រុងភ្នំពេញ<br>• យុវជនចំនួន ៥០ នាក់មកពីកាកបាទក្រហមកម្ពុជានៅភ្នំពេញ<br>• អ្នកសង្កេតការណ៍បរទេស ១៤ រូប |

**ខ. ការគ្រប់គ្រងពេលវេលា**

អង្គជំនុំជម្រះ បានបង្ហាញពីការបត់បែនមួយចំនួន ទាក់ទងនឹងការគ្រប់គ្រងពេលវេលានៅសប្តាហ៍នេះ។ មានការកត់សម្គាល់ឃើញពីការបត់បែននេះ ជាពិសេស នៅពេលដែលអង្គជំនុំជម្រះ បានផ្តល់ពេលសម្រាកបន្ថែម ឬផ្អាកសវនាការមុនម៉ោង ដើម្បីសម្រួលបញ្ហាសុខភាពរបស់សាក្សី **នូ ម៉ៅ**។ ក៏មានការផ្តល់ម៉ោងបន្ថែមដល់អយ្យការ ដើម្បីធ្វើការសាកសួរផងដែរ។ ទោះជាយ៉ាងណា ភាពបត់បែនរបស់អង្គជំនុំជម្រះ ក៏ត្រូវបានធ្វើឲ្យមានតុល្យភាពសម្រាប់ភាគី តាមរយៈការគ្រប់គ្រងយ៉ាងតឹងរ៉ឹងចំពោះការសាកសួរដដែលៗពីសំណាក់ភាគីនានា ដែលបង្ហាញពីបំណងឲ្យដំណើរការនីតិវិធី ធ្វើឡើងបានយ៉ាងរលូន ហើយលឿន។

**គ. បរិយាកាសនៅក្នុងបន្ទប់តុលាការ**

នៅសប្តាហ៍នេះ អ្នកឃ្លាំងមើលសវនាការ បានសង្កេតឃើញថា អ្នកចូលស្តាប់សវនាការទេ ដែលបង្ហាញពីបរិយាកាសមិនល្អនៅក្នុងពេលមួយចំនួន មិនមែនភាគីនៃតុលាការទេ។ កាលពីព្រឹកថ្ងៃព្រហស្បតិ៍ អ្នកតាមដានបានសង្កេតឃើញថា សិស្សមួយចំនួនបានរំខានដល់ដំណើរការនីតិវិធី មិនតែប៉ុណ្ណោះ មានឮទូរសព្ទដៃរោទិ៍ចេញពីកាសស្តាប់ និងនៅក្នុងសាលសាធារណជន។

**ឃ. ការបកប្រែ និងបញ្ហាបច្ចេកទេស**

មានបញ្ហាតិចតួចទាក់ទងនឹងការបកប្រែនៅសប្តាហ៍នេះ ដោយសារតែអ្នកនិយាយ បាននិយាយលឿនពេក ហើយនិងការហៅឈ្មោះជាភាសាខ្មែរ។ អ្នកតាមដានបានកត់សម្គាល់ឃើញថា បញ្ហានេះអាចកាត់បន្ថយបាន ប្រសិនបើមេធាវីជាតិជាអ្នកហៅឈ្មោះ ប្រសើរជាជាងឲ្យមេធាវីអន្តរជាតិជាអ្នកហៅ។ កាលពីថ្ងៃចន្ទ មន្ត្រីបកប្រែផ្ទាល់មាត់បានស្នើអ្នកនិយាយនៅក្នុងបន្ទប់តុលាការឱ្យបន្ថយល្បឿន។ ការយល់ច្រឡំជាបន្តបន្ទាប់ក៏កើតមានឡើង ដោយសារពុំមានភាពច្បាស់លាស់ថាតើ **ហ្គីសសេ** កំពុងសួរសាក្សី **ឡេង ឈឿង** អំពី **សុផាង** ហៅ "**ផាង**" ឬ **ប៉ាង** អតីតប្រធានការិយាល័យ ៨៧០។ ហេតុការណ៍ស្រដៀងគ្នា ក៏បានកើតឡើងនៅថ្ងៃពុធ នៅពេលព្រះរាជអាជ្ញា **វេយ៍ន័រ** សំដៅលើមេបញ្ជាការកងអនុសេនាធំ ដែលគាត់ហៅឈ្មោះថា "**ម៉េត**" ជូនឲ្យសាក្សី **នូ**

**ម៉ៅ** ស្តាប់។ បន្ទាប់ពីឆ្លើយឆ្លងគ្នាច្រើនដង សាក្សីក៏បានបញ្ជាក់ថា បុគ្គលដែលមានការជាប់ពាក់ព័ន្ធចោទសួរ គឺឈ្មោះ "**ម៉ាត**"។ បញ្ហាបច្ចេកទេសក៏កើតមាននៅថ្ងៃពុធ ក្នុងអំឡុងសម័យប្រជុំពេលរសៀល នៅពេលសំឡេងនៅក្នុងសាលសវនាការមិនឮច្បាស់ ដែលធ្វើឱ្យអ្នកចូលស្តាប់មិនអាចតាមដានដំណើរការនីតិវិធីបានល្អ។

### ង. កាលវិភាគ

| កាលបរិច្ឆេទ | ព្រឹក លើកទី១ | ព្រឹក លើកទី២ | រសៀល លើកទី១ | រសៀល លើកទី២ | ម៉ោងសរុបក្នុងសវនាការ |
|---|---|---|---|---|---|
| ថ្ងៃចន្ទ ១៧/០៦/១៣ | ៩:០៥-១០:២៩ | ១០:៥២-១២:០៣ | ១៣:៣២-១៤:៣៩ | ១៥:០០-១៥:៥៣ | ៤ ម៉ោង ៣៥ នាទី |
| ពុធ ១៩/០៦/១៣ | ៩:០២-១០:៤០ | ១១:០១-១២:០២ | ១៣:៣០-១៤:២៨ | ១៤:៥០-១៥:២១ | ៤ ម៉ោង ៨ នាទី |
| ព្រហស្បត្តិ៍ ២០/០៦/១៣ | ៩:០២-១០:២៨ | ១០:៥២-១១:២៧ | ១៣:៣៣-១៤:៣៨ | - | ៣ ម៉ោង ៦ នាទី |
| *ចំនួនម៉ោងជាមធ្យមក្នុងសវនាការ* | | | | *៤ ម៉ោង ២៥ នាទី* | |
| *ចំនួនម៉ោងសរុបក្នុងសប្តាហ៍នេះ* | | | | *១១ ម៉ោង ៤៩ នាទី* | |
| *ចំនួនសរុបនៃម៉ោង ថ្ងៃ សប្តាហ៍បើកសវនាការ* | | | | *៨៤៦ ម៉ោង ៧ នាទី* | |
| *សវនាការមានរយៈពេល ១៩១ ថ្ងៃ ក្នុងអំឡុងពេល ៦០ សប្តាហ៍* | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok. This issue of **KRT TRIAL MONITOR** was authored by Francisca Gilmore, Andrew Grant, Melanie Hyde, Sadaf Kashfi, Jessica Mawrence, Aviva Nababan, Noyel Ry, and Penelope Van Tuyl as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[*] AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East sia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Chhaya Chhin, Phalla Chhoeun, Pheakdey Chum, Melanie Hyde, Anne Lang, Aviva Nababan, Sarun Sous, Kimsan Soy, Chhayrath Tan and Penelope Van Tuyl as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] Trial Chamber. Transcript of Trial Proceedings (17 June 2013). E1/208.1 [hereinafter, 17 June Transcript]. Lines 21-24. 52.

[2] Mr. Leng Chheoung was examined in the following order: President of the Trial Chamber Nil Nonn; International Defense Counsel Anta Guisse; Judge Jean-Marc Lavergne; National Prosecutor Chan Dararasmey; International Prosecutor Vincent de Wilde d'Estmael.

[3] 17 June Transcript. Lines 22-25, 1-2. 48-49.

[4] The Witness stated that he attempted to drive Khieu Samphan to Takeo in order to inspect flood damage but the road conditions were too poor to allow them to go any further.

[5] The Witness claimed that he had heard of Ta Meal's arrest and execution considering that he was assigned to K-3 sometime in April 1978, while Ta Meal's arrest occurred sometime in May. This statement was further contradicted later on when International Prosecutor Vincent De Wilde D'Estmael produced a document from S-21 showing that Ta Meal was arrested in April 1978.

[6] The two Witnesses mentioned by Prosecutor de Wilde d'Estmael were Mr. Ros Suy (TCW-570), who testified on 25 April 2013, and Mr. Sim Hao (TCW-648), who testified on 13 June 2013. For Ros Suy's testimony, see Case 002 KRT Trial Monitor. Issue No. 57, Hearing on Evidence Week 52 (22-27 April 2013).; For Sim Hao, see Case 002 KRT Trial Monitor. Issue 62. Hearing on Evidence Week 57 (03-07 June 2013).

[7] See Case 002 KRT Trial Monitor. Issue No. 63. Hearing on Evidence Week 58 (10-14 June 2013).

[8] Mr. Nou Mao was examined in the following order: President of the Trial Chamber Nil Nonn; International Prosecutor Keith Raynor; National Civil Part Lawyer Lor Chunthy; National Defense Lawyer for Nuon Chea Son Arun; International Defense Lawyer for Nuon Chea Victor Koppe.

[9] Trial Chamber. Transcript of Trial Proceedings (20 June 2013). E1/210.1. Lines 21-22. 20.

[10] See Trial Chamber. "Announcement of remaining hearings prior to the close of evidentiary proceedings inCase 002/02 and scheduling of Final Trial Management Meeting for 13 June 2013" (31 May 2013). E288. par 6.2.

[11] See Case 002 KRT Trial Monitor. Issue 63. Hearing on Evidence Week 58 (10-14 June 2013). 6-8.

[12] Trial Chamber. Transcript of Trial Proceedings (19 June 2013). E1/209.1. Lines 1-5, 24-25. 64-65.

[13] Son Arun had been asking questions related to Witness Nou Mao's attendance in training sessions presided by Ta Mok and Chou Chet.

[14] The Prosecutor however, asserted that Ben Kiernan did not refuse to testify but rather requested to be allowed to testify by remote participation.

[15] See Internal Rules of the Extraordinary Chambers In The Courts of Cambodia, Revision 8, as revised on 3 August 2011 [hereinafter Internal Rules] Rule 80 on Preparation of the Trial. Particularly on documents, IR 80.3 provided that the 3. The Chamber may order the parties, within a prescribed time limit prior to the Initial hearing, to file documents including b). A list of exhibits they intend to offer in the case, containing a brief description of their nature and contents. d). A list of new documents which they intend to put before the Chamber with a brief description of their contents and a list of documents already on the case file, appropriately identified.

[16] Koppe objected four times to Raynor's questioning of Nou Mao. The objections referred to Raynor primarily relying on Ben Kiernan's notes of his interview with the Witness during the examination to refresh the Witness' memory on matters he professed he had forgotten about. The Prosecutor used terms like "you stated..." when confirming the content of Ben Kiernan's interviews. Koppe's objection was founded on a lack of certainty that the document, originally handwritten in English, accurately reflected Nou Mao's own words from his interview taken 31 years prior.

[17] See Internal Rules of the Extraordinary Chambers In The Courts of Cambodia, Revision 8, as revised on 3 August 2011, Rule 87. Rule 87(4) provides that during trial, at the request of a party, the Chamber may admit any new evidence that it deems conducive to ascertaining the truth so long as it is in compliance with Rule 87(3).

WSD**HANDA**CENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University

This publication was originally produced pursuant to a project supported by the War Crimes Studies Center (WCSC), which was founded at the University of California, Berkeley in 2000. In 2014, the WCSC re-located to Stanford University and adopted a new name: the WSD Handa Center for Human Rights and International Justice. The Handa Center succeeds and carries on all the work of the WCSC, including all trial monitoring programs, as well as partnerships such as the Asian International Justice Initiative (AIJI).

A complete archive of trial monitoring reports is available online at:

http://handacenter.stanford.edu/reports-list

For more information about Handa Center programs, please visit:

http://handacenter.stanford.edu